ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៥៤៧ សហវ. ខលក

ថ្ងៃ ពុធ ១៣ កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០១៩

**ជម្រាបជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ** : ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យាស្តីពីការងារស្តាបនាផ្លូវដោយចាក់ដីសពង្រីក និងលើកកម្ពស់តួថ្នល់សងខាង រួចក្រាលក្រួសក្រហម ប្រវែង ៤ ៨០០ម ទទឹង ៨ម ស្តាបនាលូបេតុងមុខកាត់ ១ម សរុបចំនួន ០៩កន្លែង (១ជួរ ចំនួន ០៨កន្លែង និង២ជួរ ចំនួន ០១កន្លែង) បំពាក់ស្លាកសញ្ញាចរាចរណ៍ ចំនួន ០៨ស្លាក ដាំបង្គោលនាំផ្លូវ ចំនួន ៣៦ដើម និងដាក់ស្លាកព័ត៌មានគម្រោង ចំនួន ០១ស្លាក ចាប់ពីគ.ម០២+០០០ ដល់គ.ម០៦+៨០០ ស្ថិតក្នុងឃុំកាហែង និងឃុំប៉ាខែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

**យោង** : -លិខិតលេខ៩០៦១ សហវ.អថ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-កំណត់ហេតុចរចាថ្លៃថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ គ.ល ក្រសួងសាធារណការ និងដឹកជញ្ជូន

-លិខិតលេខ១៧៤ សក.អល ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រគល់កិច្ចសន្យាជូននាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ ដើម្បីធ្វើការងារស្តាបនាផ្លូវដោយចាក់ដីសពង្រីក និងលើកកម្ពស់តួថ្នល់សងខាង រួចក្រាលក្រួសក្រហម ប្រវែង ៤ ៨០០ម ទទឹង ៨ម ស្តាបនាលូបេតុងមុខកាត់ ១ម សរុបចំនួន ០៩កន្លែង(១ជួរ ចំនួន ០៨កន្លែង និង២ជួរ ចំនួន ០១កន្លែង) បំពាក់ស្លាកសញ្ញាចរាចរណ៍ ចំនួន ០៨ស្លាក ដាំបង្គោលនាំផ្លូវ ចំនួន ៣៦ដើម និងដាក់ស្លាកព័ត៌មានគម្រោង ចំនួន ០១ស្លាក ចាប់ពីគ.ម០២+០០០ ដល់ គ.ម០៦+៨០០ ស្ថិតក្នុងឃុំកាហែង និងឃុំប៉ាខែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្នុងតម្លៃសរុបចំនួន ១.៨១៨.០០០.០០០រៀល (មួយពាន់ប្រាំបីរយដប់ប្រាំបីលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបាន ត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្ត ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាប និងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលនូវការរាប់អានពីខ្ញុំ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋលេខាធិការ

ជូ_វីជិត្ត

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តកំពង់ស្ពឺ
- នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ
- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកំពង់ស្ពឺ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកំពង់ស្ពឺ
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798